ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខ: ២៣៦៩៦៣/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០១៦

## គោរពជូន

### ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ

**កម្មវត្ថុ** ៖ ជំរុញការគាំទ្រ និងពង្រឹងការអនុវត្តមូលនិធិឃុំ សង្កាត់ផ្នែកសេវាសង្គម គាំទ្រដោយអង្គការយូនីសេហ្វ UNICEF ។

**យោង** ៖ របាយការណ៍នៃការចុះតាមដាន និងគាំទ្រដំណើរការអនុវត្តមូលនិធិឃុំ សង្កាត់ផ្នែកសេវាសង្គម គាំទ្រដោយអង្គការយូនីសេហ្វ UNICEF ។

សេចក្ដីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាង ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា កន្លងមកក្រុមការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប សហការជាមួយមន្ត្រីនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ និងមន្ត្រីនៃអង្គការយូនីសេហ្វ បានចុះតាមដាន និងគាំទ្រក្នុងខេត្តគោលដៅចំនួនពីរ ក្នុងនោះមានខេត្តកំពង់ធំផងដែរ។ ក្រុមការងារក៏បានរកឃើញបញ្ហាប្រឈមមួយចំនួន ដែលធ្វើឱ្យមានភាពអសកម្មដល់ដំណើរការអនុវត្តមូលនិធិឃុំ សង្កាត់ផ្នែកសេវាសង្គម គាំទ្រដោយអង្គការយូនីសេហ្វ UNICEF ។ ដើម្បីធានាឱ្យដំណើរការនៃការអនុវត្តនេះកាន់តែល្អប្រសើរ ដូច្នេះ លេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការណែនាំដូចខាងក្រោម៖

- ធានាឱ្យមានការបន្តអនុវត្តថវិកាអតិរេកនៅដើមឆ្នាំបន្ទាប់ (ជាពិសេសក្នុងត្រីមាសទី១ និងត្រីមាសទី២) របស់មូលនិធិឃុំ សង្កាត់ផ្នែកសេវាសង្គមដែលគាំទ្រដោយអង្គការយូនីសេហ្វ UNICEF តាមរយៈការពង្រឹងកិច្ចសហការរវាងទីប្រឹក្សាខេត្ត ជាមួយគណនេយ្យករឃុំ សង្កាត់ ដើម្បីគាំទ្រ និងពង្រឹងសមត្ថភាពមន្ត្រីសេវាសង្គម ទីប្រឹក្សា និងបុគ្គលិកគាំទ្របច្ចេកទេសថ្នាក់ស្រុកក្នុងការរៀបចំ និងការអនុវត្តមូលនិធិឃុំ សង្កាត់ផ្នែកសេវាសង្គម (ដូចជា គណនេយ្យករឃុំ សង្កាត់ និងទីប្រឹក្សាហិរញ្ញវត្ថុខេត្តគួរពន្យល់ឬណែនាំដល់ឃុំ សង្កាត់ឱ្យដូចគ្នានូវនីតិវិធីហិរញ្ញវត្ថុឃុំ សង្កាត់ ការដកសាច់ប្រាក់ ការទូទាត់ ពិសេសការប្រើប្រាស់ថវិកាអតិរេកជាដើម) ។
- ពង្រឹងការតាមដាន ត្រួតពិនិត្យការបំពេញការងាររបស់ទីប្រឹក្សា មន្ត្រីសេវាសង្គម បុគ្គលិកគាំទ្របច្ចេកទេសថ្នាក់ស្រុក ជាពិសេសសម្រាប់ឃុំដែលមានសមត្ថភាពទន់ខ្សោយដែលតម្រូវឱ្យមានការគាំទ្រជាប្រចាំ និងជំរុញការកសាង ការអនុវត្តផែនការសកម្មភាព និងការរៀបចំឯកសារទូទាត់របស់ គ.ក.ន.ក និងស្នើទៅរតនាគារខេត្តឱ្យបានទៀងទាត់តាមការកំណត់ និងទាន់ពេលវេលា ។

មហាវិថីព្រះនរោត្តម: លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ : (៨៥៥-២៣) ៧២០ ០៦១/៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038

- ពង្រឹងការតាមដាន និងកិច្ចសហការជាមួយរតនាគារខេត្ត ដើម្បីជំរុញការពិនិត្យឯកសារទូទាត់ ការផ្តល់ព័ត៌មានត្រឡប់ទៅឃុំ សង្កាត់ឱ្យបានជាប្រចាំអំពីស្ថានភាពនៃឯកសារដែលបានពិនិត្យដោយគណនេយ្យករឃុំ សង្កាត់ក្នុងរយៈពេលសមស្របមួយ (ឧ. យ៉ាងយូរមួយសប្តាហ៍) ។
- តាមរយៈមន្ត្រីសេវាសង្គម ទីប្រឹក្សា និងបុគ្គលិកគាំទ្របច្ចេកទេសថ្នាក់ស្រុក ត្រូវពង្រឹងការតាមដានការអនុវត្តតួនាទី ភារកិច្ច និងការចូលរួមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពិសេសមន្ត្រីបង្គោលទទួលបន្ទុក គ.ក.ន.ក ក្នុងការកសាង និងការអនុវត្តផែនការ ការទូទាត់មូលនិធិឃុំ សង្កាត់ផ្នែកសេវាសង្គម ការជ្រើសរើសយកអ្នកទទួលផលដោយផ្អែកលើទិន្នន័យច្បាស់លាស់ដូចជា ផែនទីសេវាសង្គម ឬ ប័ណ្ណក្រីក្រ និងធានាឱ្យមានតម្លាភាព និងគណនេយ្យភាព ។
- ជំរុញក្រុមប្រឹក្សាឃុំ និង គ.ក.ន.ក ឱ្យផ្សព្វផ្សាយការចុះបញ្ជីអត្រានុកូលដ្ឋាន និងការរៀបចំឯកសារដើម្បីធ្វើឱ្យប្រជាពលរដ្ឋអាចទទួលបានឯកសារអត្រានុកូលដ្ឋានឆាប់រហ័ស ។
- ពង្រឹងការចុះតាមដាន ត្រួតពិនិត្យ និងគាំទ្រជាប្រចាំរបស់មន្ត្រីសេវាសង្គមខេត្ត ស្រុក ទីប្រឹក្សា និងបុគ្គលិកគាំទ្របច្ចេកទេសថ្នាក់ស្រុកទៅលើការគូរ ការរៀបចំ និងការធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គមតាមភូមិនីមួយៗក្នុងឃុំគោលដៅឱ្យកាន់តែមានភាពច្បាស់លាស់ និងមានគុណភាព ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តារៀបចំ ចាត់ចែង និងអនុវត្តការងារនេះ ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

អនុប្រធាន

ទ៊ន់ ចំរើន

**<u>ចម្លងជូន៖</u>**

-ក្រសួងមហាផ្ទៃ (ក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី២)

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី៤)

-អគ្គនាយកដ្ឋានរតនាគារជាតិ

-សាលាខេត្តបាត់ដំបង សៀមរាប ស្វាយរៀង កំពង់ស្ពឺ ព្រះសីហនុ រតនៈគិរី និងខេត្តឧត្តរមានជ័យ

-រតនាគារខេត្តបាត់ដំបង សៀមរាប ស្វាយរៀង កំពង់ស្ពឺ ព្រះសីហនុ រតនៈគិរី និងខេត្តឧត្តរមានជ័យ

-អង្គការយូនីសេហ្វ

-ឯកសារ-កាលប្បវត្តិ